ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្ដាល

តុលាការព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌលេខ ១២៩៤ អ.ក

ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២៣

សំណុំរឿងស៊ើបសួរលេខ ៨១៨ ស.ស

ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២៣

សំណុំរឿងជំនុំជម្រះលេខ ១៥២៨ ជ.រ

ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២៣

សាលក្រមព្រហ្មទណ្ឌលេខ ៣៧ /ឈ

ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៤

# សាលក្រម

## ក្នុងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តកណ្ដាល

| | |
|---|---|
| កាលបរិច្ឆេទនៃសវនាការ | ៖ ថ្ងៃទី៦ ខែមីនា ឆ្នាំ២០២៤។ |
| សាលសវនាការ និងពេលវេលា | ៖ សាល ៥ ម៉ោង ២ រសៀល។ |
| កាលបរិច្ឆេទនៃការប្រកាសសាលក្រម | ៖ ថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៤។ |
| សាលសវនាការ និងពេលវេលា | ៖ សាល ៥ ម៉ោង ៩ ព្រឹក។ |

ក្រោមសមាសភាពជំនុំជម្រះ រួមមាន៖

### ក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកណ្ដាល និងជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកណ្ដាល និងជាចៅក្រមប្រឹក្សា

លោក [redacted] ក្រមសាលាដំបូងខេត្តកណ្ដាល និងជាចៅក្រមប្រឹក្សា

### តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តកណ្ដាល

### ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីនៃសាលាដំបូងខេត្តកណ្ដាល

**ក. អំពីអត្តសញ្ញាណជនជាប់ចោទ**

១. ឈ្មោះ [redacted] **ចិត្រា** ភេទប្រុស កើតឆ្នាំ១៩៩៦ (អាយុ ២៧ ឆ្នាំ) ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរជាងដែក។

ទីកន្លែងកំណើតនៅភូ[redacted] ខេត្តកណ្ដាល។

ទីលំនៅភូមិ[redacted] ខេត្តកណ្ដាល។

ឪពុកឈ្មោះ [redacted] **ផាត** (រ) ម្ដាយឈ្មោះ [redacted] **ចាន់ធារី** (រ) ប្រពន្ធឈ្មោះ [redacted] **បុប្ផា** មានកូន ២ នាក់។

ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការ៖ ធ្លាប់ជាប់ពន្ធនាគាររយៈពេល ២ ឆ្នាំ ៨ ខែ។ **(ក្នុងឃុំ)**

កាលបរិច្ឆេទនៃការឃាត់ខ្លួន៖ ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣។

កាលបរិច្ឆេទនៃការឃុំខ្លួនជាបណ្ដោះអាសន្ន៖ ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២៣។

កាលបរិច្ឆេទនៃការរក្សាទុកក្នុងការឃុំខ្លួនជាបណ្ដោះអាសន្ន៖ ថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០២៣។



Scanned with CamScanner

**២.** ឈ្មោះ [redacted] **ជីវ័ន្ត** ភេទប្រុស កើតឆ្នាំ២០០៧ (អាយុ ១៦ ឆ្នាំ) ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរកម្មករ។

ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តកណ្ដាល។

ទីលំនៅភូមិ [redacted] ខេត្តកណ្ដាល។

ឪពុកឈ្មោះ [redacted] **យុទ្ធណារុធ** (ស) ម្ដាយឈ្មោះ **ឆាំ ស៊ីថា** (ស) ប្រពន្ធឈ្មោះ [redacted] **ស្រីល័ក្ខ** គ្មានកូន។

ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការ៖ គ្មាន។ **(ក្នុងឃុំ)**

កាលបរិច្ឆេទនៃការឃាត់ខ្លួន៖ ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣។

កាលបរិច្ឆេទនៃការឃុំខ្លួនជាបណ្ដោះអាសន្ន៖ ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២៣។

កាលបរិច្ឆេទនៃការរក្សាទុកក្នុងការឃុំខ្លួនជាបណ្ដោះអាសន្ន៖ ថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០២៣។

**៣.** ឈ្មោះ [redacted] **សុខជា** ភេទប្រុស កើតឆ្នាំ១៩៩៤ (អាយុ ២៩ ឆ្នាំ) ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរកម្មករ។

ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តកណ្ដាល។

ទីលំនៅភូមិ [redacted] ខេត្តកណ្ដាល។

ឪពុកឈ្មោះ [redacted] **វណ្ណៈ** (រ) ម្ដាយឈ្មោះ [redacted] **ចាន់ផល្លី** (រ) ពោះម៉ាយ មានកូន ១ នាក់។

ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការ៖ គ្មាន។ **(ក្នុងឃុំ)**

កាលបរិច្ឆេទនៃការឃាត់ខ្លួន៖ ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣។

កាលបរិច្ឆេទនៃការឃុំខ្លួនជាបណ្ដោះអាសន្ន៖ ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២៣។

កាលបរិច្ឆេទនៃការរក្សាទុកក្នុងការឃុំខ្លួនជាបណ្ដោះអាសន្ន៖ ថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០២៣។

**៤.** ឈ្មោះ [redacted] **វណ្ណណា** ភេទប្រុស កើតឆ្នាំ២០០២ (អាយុ ២១ ឆ្នាំ) ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរជាងសំណង់។

ទីកន្លែងកំណើតនៅភូមិព្រែក [redacted] ខេត្តកណ្ដាល។

ទីលំនៅភូមិព្រែក [redacted] ខេត្តកណ្ដាល។

ឪពុកឈ្មោះ [redacted] **ដារ៉ា** (រ) ម្ដាយឈ្មោះ [redacted] **ចន្ថា** (រ) នៅលីវ។

ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការ៖ គ្មាន។ **(ក្នុងឃុំ)**

កាលបរិច្ឆេទនៃការឃាត់ខ្លួន៖ ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣។

កាលបរិច្ឆេទនៃការឃុំខ្លួនជាបណ្ដោះអាសន្ន៖ ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២៣។

កាលបរិច្ឆេទនៃការរក្សាទុកក្នុងការឃុំខ្លួនជាបណ្ដោះអាសន្ន៖ ថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០២៣។

**៥.** ឈ្មោះ [redacted] **សីហោ** ហៅ **ទ្រី** ភេទប្រុស កើតឆ្នាំ១៩៨៣ (អាយុ ៤០ ឆ្នាំ) ជនជាតិខ្មែរ សញ្ជាតិខ្មែរ។

ទីលំនៅសង្កាត់ [redacted] ខេត្តកណ្ដាល។ **(គេចខ្លួន)**

ជាប់ចោទពីបទ **រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិលេខ១ សង្កាត់ស្វាយរលំ ក្រុងតាខ្មៅ ខេត្តកណ្ដាល កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្ដន្ទាទោសតាមមាត្រា ៤០ មាត្រា ៤៥ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។



Scanned with CamScanner

**មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ៖**

លោកមេធាវី [redacted] ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

ការិយាល័យប្រតិភូគណៈមេធាវីប្រចាំខេត្តកណ្តាល។

**សំណុំរឿងព្រហ្មទណ្ឌនេះបញ្ជូនមកជំនុំជម្រះតាមដីកាដំណោះស្រាយលេខ ១៤២៥ ដក.ដស ចុះថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្តាល ដែលមាន៖**

**អង្គហេតុដែលប្តឹងមកតុលាការ**

នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣ វេលាម៉ោង ១២ និង ៣០ នាទី កម្លាំងប៉ុស្តិ៍នគរបាលរដ្ឋបាលស្វាយរលំ បានចេញល្បាតតាមភូមិសាស្ត្រ មកដល់ចំណុចភូមិលេខ១ សង្កាត់ស្វាយរលំ ក្រុងតាខ្មៅ ខេត្តកណ្តាល បានប្រទះឃុំជនចំនួន ៤ (បួន) នាក់ ឈ្មោះ [redacted] **ចិត្រា** ភេទប្រុស អាយុ ២៧ ឆ្នាំ ឈ្មោះ [redacted] **ជីវ័ន្ត** ភេទប្រុស អាយុ ១៧ ឆ្នាំ ឈ្មោះ [redacted] **សុខជា** ភេទប្រុស អាយុ ២៩ ឆ្នាំ និងឈ្មោះ [redacted] **វឌ្ឍនា** ភេទប្រុស អាយុ ២១ ឆ្នាំ កំពុងជុំគ្នាប្រើប្រាស់ថ្នាំញៀន។ បន្ទាប់មកកម្លាំងសមត្ថកិច្ចក៏បានឃាត់ឆែកឆេររកថ្នាំញៀនចំនួន ១ (មួយ) កញ្ចប់ និងឧបករណ៍សម្រាប់ប្រើប្រាស់ថ្នាំញៀនមួយចំនួន នៅក្បែរខ្លួនរបស់ជនទាំង ៤ (បួន) នាក់ ហើយកម្លាំងសមត្ថកិច្ចក៏បានឃាត់ខ្លួនជនទាំង ៤ (បួន) នាក់ បញ្ជូនមកកាន់អធិការដ្ឋាននគរបាលក្រុងតាខ្មៅ ដើម្បីចាត់ការតាមនីតិវិធីច្បាប់។ ជនទាំង ៤ (បួន) នាក់ខាងលើបានឆ្លើយថា ថ្នាំញៀនចំនួន ១ (មួយ) កញ្ចប់ខាងលើនេះ គឺជារបស់ឈ្មោះ [redacted] **សីហោ** ហៅ **ទ្រី** ភេទប្រុស អាយុ ៤០ ឆ្នាំ។ ក្រោយឃាត់ខ្លួនសមត្ថកិច្ចក៏បានធ្វើតេស្តទឹកនោមលើជនទាំង ៤ នាក់ ហើយលទ្ធផលបានបញ្ជាក់ថាមានសារធាតុញៀននៅក្នុងទឹកនោមនោះផងដែរ។

**អំពីកិច្ចពិភាក្សាដេញដោលលើអង្គសេចក្តី**

**ក. អំពីកិច្ចពិភាក្សាដេញដោលមុនពេលអង្គសេចក្តី**

អំពីវិវាទកម្មស្តីពីនិយតភាពនៃការកោះហៅ តាមមាត្រា ៣២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖ គ្មាន។

អំពីអញ្ញត្រកម្ម តាមមាត្រា ៣៤២ ដល់មាត្រា ៣៤៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖ គ្មាន។

**ខ. អំពីកិច្ចពិភាក្សាដេញដោលលើអង្គសេចក្តី**

**១. ការសួរចម្លើយជនជាប់ចោទ**

**១.១.** ឈ្មោះ [redacted] **ចិត្រា** ក្នុងកិច្ចពិភាក្សាដេញដោល៖ ខ្ញុំបាទពិតជាបានប្រព្រឹត្តដូចការចោទពិតប្រាកដមែន។ កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣ វេលាម៉ោង ៩ នាទីព្រឹក ខ្ញុំបាទកំពុងដេកនៅក្រោមផ្ទះរបស់ឈ្មោះ [redacted] **ជីវ័ន្ត** ស្រាប់តែមានសមត្ថកិច្ចបានមកដល់ ហើយបានធ្វើការសាកសួរ និងបានធ្វើការឃាត់ខ្លួនខ្ញុំបាទពេលនោះតែម្តង។ ហើយចំពោះថ្នាំញៀនដែលសមត្ថកិច្ចដកហូតបានគឺពុំមែនជារបស់ខ្ញុំបាទនោះទេ។ ខ្ញុំបាទធ្លាប់បានប្រើប្រាស់ថ្នាំញៀនអស់រយៈពេល ៣ ឆ្នាំ មកហើយ។

**១.២.** ឈ្មោះ [redacted] **ជីវ័ន្ត** ក្នុងកិច្ចពិភាក្សាដេញដោល៖ ខ្ញុំពិតជាបានប្រព្រឹត្តដូចការចោទពិតប្រាកដមែន។ កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣ វេលាម៉ោង ៩ ព្រឹក ខ្ញុំបាទកំពុងលាងចាននៅផ្ទះរបស់ខ្ញុំស្រាប់តែខ្ញុំបានឃើញឈ្មោះ [redacted] **សុខជា** ឈ្មោះ [redacted] **វឌ្ឍនា** និងឈ្មោះ [redacted] **សីហោ** ហៅ **ទ្រី** បាននាំគ្នារត់កាត់ផ្ទះរបស់ខ្ញុំ



Scanned with CamScanner

ដោយមានសមត្ថកិច្ចរត់ដេញតាមចាប់ពីក្រោយ។ លុះមួយសន្ទុះក្រោយមកសមត្ថកិច្ចក៏បានមកផ្ទះរបស់ខ្ញុំ ហើយបានធ្វើការសាកសួរ និងបានធ្វើការឃាត់ខ្លួនខ្ញុំចោទពេលនោះតែម្តង។ ចំពោះថ្នាំញៀន គឺជារបស់ឈ្មោះ [redacted] **សីហោ** ហៅ **ទ្រី**។ ខ្ញុំបាទធ្លាប់បានប្រើប្រាស់ថ្នាំញៀនអស់រយៈពេល ៦ ខែ មកហើយ។

**១.៣. ឈ្មោះ [redacted] សុខជា** ក្នុងកិច្ចពិភាក្សាដេញដោល៖ ខ្ញុំពិតជាបានប្រព្រឹត្តដូចការចោទពិតមែន។ ថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ២០២៣ វេលាម៉ោង ៩ ព្រឹក ខ្ញុំកំពុងលេងណេតនៅខាងក្រោមផ្ទះរបស់ឈ្មោះ [redacted] **ជីវ័ន្ត** លុះបានមួយសន្ទុះស្រាប់តែឃើញឈ្មោះ [redacted] **សីហោ** ហៅ **ទ្រី** រត់មកកាត់ផ្ទះរបស់ឈ្មោះ [redacted] **ជីវ័ន្ត** ពេលនោះសមត្ថកិច្ចកំពុងរត់ដេញចាប់ឈ្មោះ [redacted] **សីហោ** ហៅ **ទ្រី** មួយសន្ទុះក្រោយមកសមត្ថកិច្ចក៏បានមកដល់ផ្ទះរបស់ឈ្មោះ [redacted] **ជីវ័ន្ត** ហើយបានមកសាកសួរខ្ញុំបាទ និងបានឃាត់ខ្លួនខ្ញុំបាទពេលនោះតែម្តង។ ចំពោះថ្នាំញៀនគឺជារបស់ឈ្មោះ [redacted] **សីហោ** ហៅ **ទ្រី**។ ខ្ញុំបាទធ្លាប់បានប្រើប្រាស់ថ្នាំញៀនអស់រយៈពេល ៤ ខែ មកហើយ។

**១.៤. ឈ្មោះ [redacted] វឌ្ឍនា** ក្នុងកិច្ចពិភាក្សាដេញដោល៖ ខ្ញុំពិតជាបានប្រព្រឹត្តដូចការចោទពិតមែន។ ថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ២០២៣ វេលាម៉ោង ៩ ព្រឹក ខ្ញុំកំពុងលេងណេតស្រាប់តែមានសមត្ថកិច្ចបានមកដល់ ហើយបានសាកសួរខ្ញុំបាទ និងបានឃាត់ខ្លួនខ្ញុំបាទពេលនោះតែម្តង។ ចំពោះថ្នាំញៀនគឺជារបស់ឈ្មោះ [redacted] **សីហោ** ហៅ **ទ្រី**។ ខ្ញុំបាទធ្លាប់បានប្រើប្រាស់ថ្នាំញៀនអស់រយៈពេល ៦ ខែ មកហើយ ប៉ុន្តែខ្ញុំបាទមិនដែលបានប្រើប្រាស់ថ្នាំញៀនជាមួយនឹងឈ្មោះ [redacted] **សុខជា** ឈ្មោះ [redacted] **ចិត្រា** ឈ្មោះ [redacted] **ជីវ័ន្ត** និងឈ្មោះ [redacted] **សីហោ** ហៅ **ទ្រី** នោះទេ ហើយខ្ញុំបាទក៏ពុំធ្លាប់បានធ្វើការលក់ដូរថ្នាំញៀននោះដែរ។

### សិទ្ធិនិយាយស្តីរបស់ភាគី បន្ទាប់ពីចប់កិច្ចពិភាក្សាដេញដោល

**ក. ការកត់សម្គាល់ខ្លីៗរបស់៖**

១. ជនជាប់ចោទឈ្មោះ [redacted] **ចិត្រា** ស្នើសុំឱ្យតុលាការជួយបន្ធូរបន្ថយទោស។

២. ជនជាប់ចោទឈ្មោះ [redacted] **ជីវ័ន្ត** ស្នើសុំឱ្យតុលាការជួយបន្ធូរបន្ថយទោស។

៣. ជនជាប់ចោទឈ្មោះ [redacted] **សុខជា** ស្នើសុំឱ្យតុលាការជួយបន្ធូរបន្ថយទោស។

៤. ជនជាប់ចោទឈ្មោះ [redacted] **វឌ្ឍនា** ស្នើសុំឱ្យតុលាការជួយបន្ធូរបន្ថយទោស។

៥. ជនជាប់ចោទឈ្មោះ [redacted] **សីហោ** ហៅ **ទ្រី** អវត្តមានសវនាការ។

**ខ. សេចក្តីសន្និដ្ឋាន៖**

**១. សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ៖**

ក្រោយពេលកិច្ចពិភាក្សាដេញដោលរួចមក និងពិនិត្យរបាយការណ៍សមត្ថកិច្ច ឃើញថា មានភាពស៊ីចង្វាក់គ្នាអាចឱ្យតំណាងអយ្យការរក្សាការចោទប្រកាន់ទុកជាបានការដដែល។ តំណាងអយ្យការប្តឹងសុំឱ្យតុលាការសម្រេចតាមច្បាប់។

**២. សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ៖**

នៅក្នុងកិច្ចពិភាក្សាដេញដោល កូនក្តីខ្ញុំបាទបានសារភាពថា ពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន ដូច្នេះក្នុងនាមខ្ញុំជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ស្នើសុំតុលាការបន្ធូរបន្ថយទោស។



Scanned with CamScanner

- *ក្រោយពីបាន ស្ដាប់កិច្ចពិភាក្សាដេញដោលរួចហើយ*
- *ក្រោយពីបាន ស្ដាប់សិទ្ធិនិយាយស្ដីរបស់ភាគី បន្ទាប់ពីចប់កិច្ចពិភាក្សាដេញដោល*

**សំអាងហេតុ**

**ក. អំពីសមត្ថកិច្ចនៃការជំនុំជម្រះរឿងក្ដី**

សាលាដំបូងខេត្តកណ្ដាលបានទទួលសំណុំរឿងព្រហ្មទណ្ឌលេខ **១២៩៤ អ.ក** ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២៣ ដែលមានជនជាប់ចោទឈ្មោះ [redacted] **ចិត្រា** ភេទប្រុស កើតឆ្នាំ១៩៩៦ (អាយុ ២៧ ឆ្នាំ) ឈ្មោះ [redacted] **ជីវ័ន្ត** ភេទប្រុស កើតឆ្នាំ២០០៧ (អាយុ ១៦ ឆ្នាំ) ឈ្មោះ [redacted] **សុខជា** ភេទប្រុស កើតឆ្នាំ១៩៩៤ (អាយុ ២៩ ឆ្នាំ) ឈ្មោះ [redacted] **វណ្ណណា** ភេទប្រុស កើតឆ្នាំ២០០២ (អាយុ ២១ ឆ្នាំ) ឈ្មោះ [redacted] **សីហោ** ហៅ **ទ្រី** ភេទប្រុស កើតឆ្នាំ១៩៨៣ (អាយុ ៤០ ឆ្នាំ) ដូចមានអត្តសញ្ញាណខាងលើ មកជំនុំជម្រះពីបទ **រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិលេខ១ សង្កាត់ស្វាយរលំ ក្រុងតាខ្មៅ ខេត្តកណ្ដាល កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្ដន្ទាទោសតាមមាត្រ ៤០ និងមាត្រា ៤៥ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន តាមដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរ តាមមាត្រា ២៩១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលនាំឱ្យសាលាដំបូងខេត្តកណ្ដាលមានសមត្ថកិច្ចក្នុងការជំនុំជម្រះ៕

**ខ. អំពីដែនកំណត់នៃការប្ដឹងចំពោះអង្គហេតុ និងបុគ្គល**

ដែនកំណត់នៃការប្ដឹងទៅតុលាការចំពោះអង្គហេតុ តាមដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះរបស់ចៅក្រមស៊ើបសួរ តាមមាត្រា ៣៤៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងដែនកំណត់នៃការប្ដឹងទៅតុលាការចំពោះបុគ្គល តាមមាត្រា ៣៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលនាំឱ្យសាលាដំបូងខេត្តកណ្ដាល មានសមត្ថកិច្ចក្នុងការជំនុំជម្រះលើ អង្គហេតុដែលប្ដឹងមកតុលាការ និងចំពោះជនជាប់ចោទឈ្មោះ [redacted] **ចិត្រា** ឈ្មោះ [redacted] **ជីវ័ន្ត** ឈ្មោះ [redacted] **សុខជា** ឈ្មោះ [redacted] **វណ្ណនា** និងឈ្មោះ [redacted] **សីហោ** ហៅ **ទ្រី**៕

**គ. អំពី ពិរុទ្ធភាព**

១. តាមឯកសារសំណុំរឿងរបស់មន្ត្រីនគបាលយុត្តិធម៌ដែលជាឯកសារបន្ទាល់ និងតាមចម្លើយជនជាប់ចោទឈ្មោះ [redacted] **ចិត្រា** ឈ្មោះ [redacted] **ជីវ័ន្ត** ឈ្មោះ [redacted] **សុខជា** ឈ្មោះ [redacted] **វណ្ណនា** ឈ្មោះ [redacted] **សីហោ** នៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ នៅចំពោះមុខតំណាងអយ្យការ នៅចំពោះមុខចៅក្រមស៊ើបសួរ និងនៅក្នុងកិច្ចពិភាក្សាដេញដោលបង្ហាញថា អង្គហេតុដែលប្ដឹងមកតុលាការ គឺជាអង្គហេតុពិតប្រាកដដែលបានកើតឡើង។

**២.** តាមសំអាងហេតុចំណុចទី១ នៃចំណុច គ (អំពីពិរុទ្ធភាព) ខាងលើ បង្ហាញថា អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] **ចិត្រា** ឈ្មោះ [redacted] **ជីវ័ន្ត** ឈ្មោះ [redacted] **សុខជា** ឈ្មោះ [redacted] **វណ្ណនា** ឈ្មោះ [redacted] **សីហោ** បានបំពេញធាតុសត្យានុម័តនៃបទ **រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិលេខ១ សង្កាត់ស្វាយរលំ ក្រុងតាខ្មៅ ខេត្តកណ្ដាល កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្ដន្ទាទោសតាមមាត្រ ៤០ កថាខណ្ឌទី១ ទី៤ និងមាត្រា ៤៥ កថាខណ្ឌទី១ នៃ



Scanned with CamScanner

ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដោយហេតុថា ជនជាប់ចោទបានកាន់កាប់ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន។

៣. តាមសំអាងហេតុចំណុចទី១ ដល់ទី២ នៃចំណុច គ (អំពីពិរុទ្ធភាព) ខាងលើ បង្ហាញថា អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] **ចិត្រា** ឈ្មោះ [redacted] **ជីវ័ន្ត** ឈ្មោះ [redacted] **សុខជា** ឈ្មោះ [redacted] **វណ្ណនា** ឈ្មោះ [redacted] **សីហោ** បានបំពេញធាតុអត្តនោម័តនៃបទ **រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិលេខ១ សង្កាត់ស្វាយរលំ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្តន្ទាទោសតាមមាត្រ ៤០ កថាខណ្ឌទី១ ទី៤ និងមាត្រា ៤៥ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងដែលជាចេតនាទុច្ចរិតក្នុងការប្រព្រឹត្តបទល្មើសតាមមាត្រា ៤ នៃក្រមព្រហ្មទណ្ឌ។

៤. តាមសំអាងហេតុចំណុចទី១ និងទី៣ នៃចំណុច គ (អំពីពិរុទ្ធភាព) ខាងលើ បង្ហាញថា អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] **ចិត្រា** ឈ្មោះ [redacted] **ជីវ័ន្ត** ឈ្មោះ [redacted] **សុខជា** ឈ្មោះ [redacted] **វណ្ណនា** ឈ្មោះ [redacted] **សីហោ** បានបំពេញធាតុផ្សំនៃបទ **រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិលេខ១ សង្កាត់ស្វាយរលំ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្តន្ទាទោសតាមមាត្រ ៤០ កថាខណ្ឌទី១ ទី៤ និងមាត្រា ៤៥ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន៕

**ឃ. អំពីការទទួល ឬមិនទទួលខុសត្រូវព្រហ្មទណ្ឌ**

តាមរយៈភស្តុតាងក្នុងសំណុំរឿង ពុំមានភស្តុតាងណាមួយដែលអាចបញ្ជាក់បានថា នៅពេលកំពុងប្រព្រឹត្តបទល្មើស ជនជាប់ចោទ កើតមានវិបល្លាសស្មារតី ដែលធ្វើឱ្យបាត់បង់ដឹងខុសត្រូវរបស់ខ្លួន បន្ថយនូវការដឹងខុសត្រូវរបស់ខ្លួន ដោយសារការប្រើប្រាស់គ្រឿងស្រវឹង គ្រឿងញៀន ឬសារជាតិដែលច្បាប់ហាមឃាត់ តាមមាត្រា ៣១ នៃក្រមព្រហ្មទណ្ឌ។ ហេតុនេះ ជនជាប់ចោទ ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើដែលខ្លួនបានប្រព្រឹត្តតាមមាត្រា ២៤ និងមាត្រា ៣៨ នៃក្រមព្រហ្មទណ្ឌ៕

**ង. អំពី ការប្រកាសអំពីពិរុទ្ធភាព**

តាមសំអាងហេតុចំណុច គ (អំពី ពិរុទ្ធភាព) និងចំណុច ឃ (អំពីការទទួលខុសត្រូវព្រហ្មទណ្ឌ) ខាងលើ បង្ហាញថា ជនជាប់ចោទឈ្មោះ [redacted] **ចិត្រា** ឈ្មោះ [redacted] **ជីវ័ន្ត** ឈ្មោះ [redacted] **សុខជា** ឈ្មោះ [redacted] **វណ្ណនា** ឈ្មោះ [redacted] **សីហោ** បានបំពេញធាតុផ្សំនៃបទ **រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិលេខ១ សង្កាត់ស្វាយរលំ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្តន្ទាទោសតាមមាត្រ ៤០ កថាខណ្ឌទី១ ទី៤ និងមាត្រា ៤៥ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមានលក្ខខណ្ឌគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌ ហេតុដូច្នេះ តុលាការយល់ឃើញថា ជនជាប់ចោទឈ្មោះ [redacted] **ចិត្រា** ឈ្មោះ [redacted] **ជីវ័ន្ត** ឈ្មោះ [redacted] **សុខជា** ឈ្មោះ [redacted] **វណ្ណនា** ឈ្មោះ [redacted] **សីហោ** មានពិរុទ្ធភាពពីបទ **រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិលេខ១ សង្កាត់ស្វាយរលំ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃ

ទី២៨ ខែកក្កដា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្ដន្ទាទោសតាមមាត្រ ៤០ កថាខណ្ឌទី១ ទី៤ និងមាត្រា ៤៥ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន៕

**ច. អំពីការពិចារណាលើស្ថានសម្រាល និងស្ថានទម្ងន់ទោស**

អំពើរបស់ជនជាប់ចោទ មិនបានបង្កើតឱ្យមានស្ថានទម្ងន់ទោសណាមួយចំពោះជនជាប់ចោទតាមមាត្រា ៨៣ ដល់មាត្រា ៩២ នៃក្រមព្រហ្មទណ្ឌ ហេតុដូច្នេះ តុលាការនឹងសម្រេចពុំពិចារណាអំពីស្ថានទម្ងន់ទោសនោះទេ។ ចំពោះស្ថានសម្រាលទោសតាមមាត្រា ៩៤ និងមាត្រា ៩៥ នៃក្រមព្រហ្មទណ្ឌ ពុំមានភស្តុតាង ឬសញ្ញាណណាមួយដែលអាចបង្ហាញបានថា កាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈនៃជនជាប់ចោទតម្រូវ ហេតុដូច្នេះ នឹងសម្រេចពុំពិចារណាអំពីស្ថានសម្រាលទោសនោះទេ៕

**ឆ. អំពីរបបនៃការប្រកាសទោស**

**ឆ.១. ការប្រកាសអំពីមូលទោស**

តាមកាលៈទេសៈនៃបទល្មើស តាមបុគ្គលិកលក្ខណៈនៃជនជាប់ចោទ តាមសភាពផ្លូវចិត្ត តាមធនធាននិងបន្ទុក តាមមូលហេតុ ព្រមទាំងកិរិយាមារយាទរបស់ជនជាប់ចោទ ក្រោយពេលប្រព្រឹត្តបទល្មើស តុលាការនឹងសម្រេចប្រកាសមូលទោស ក្នុងទម្រង់ជាការប្រកាសទោសដាក់ពន្ធនាគារតាមមាត្រា ២៨ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដោយសម្រេចប្រកាសមូលទោសដាក់ពន្ធនាគារលើជនជាប់ចោទ៖

**១.** ឈ្មោះ [redacted] **ចិត្រា** ភេទប្រុស កើតឆ្នាំ១៩៩៦ (អាយុ ២៧ ឆ្នាំ) ដូចមានអត្តសញ្ញាណខាងលើ, ឈ្មោះ [redacted] **សុខជា** ភេទប្រុស កើតឆ្នាំ១៩៩៤ (អាយុ ២៩ ឆ្នាំ) ដូចមានអត្តសញ្ញាណខាងលើ, ឈ្មោះ [redacted] **វណ្ណណា** ភេទប្រុស កើតឆ្នាំ២០០២ (អាយុ ២១ ឆ្នាំ) ដូចមានអត្តសញ្ញាណខាងលើ, ឈ្មោះ [redacted] **សីហោ** ហៅ **ទ្រី** ភេទប្រុស កើតឆ្នាំ១៩៨៣ (អាយុ ៤០ ឆ្នាំ) ដូចមានអត្តសញ្ញាណខាងលើ ចំនួន **២ (ពីរ) ឆ្នាំ** ពីបទ **រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិលេខ១ សង្កាត់ស្វាយរលំ ក្រុងតាខ្មៅ ខេត្តកណ្ដាល កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្ដន្ទាទោសតាមមាត្រ ៤០ កថាខណ្ឌទី១ ទី៤ និងមាត្រា ៤៥ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ព្រោះដោយផ្អែកទៅលើកម្រិតធាតុសុទ្ធនៃសារធាតុញៀន និងកាលៈទេសៈនៃបទល្មើស។

**២.** ឈ្មោះ [redacted] **ជីវ័ន្ត** ភេទប្រុស កើតឆ្នាំ២០០៧ (អាយុ ១៦ ឆ្នាំ) ដូចមានអត្តសញ្ញាណខាងលើ ចំនួន **១ (មួយ) ឆ្នាំ** ពីបទ **រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិលេខ១ សង្កាត់ស្វាយរលំ ក្រុងតាខ្មៅ ខេត្តកណ្ដាល កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្ដន្ទាទោសតាមមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ មាត្រ ៤០ កថាខណ្ឌទី១ ទី៤ និងមាត្រា ៤៥ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ព្រោះដោយផ្អែកទៅលើកម្រិតធាតុសុទ្ធនៃសារធាតុញៀន និងកាលៈទេសៈនៃបទល្មើស។

**ឆ.២. ចំពោះរបបនៃការប្រកាសទោសផ្សេងទៀត**

ចំពោះរបបនៃការប្រកាសទោសផ្សេងទៀត តុលាការនឹងមិនលើកយកមកពិចារណានោះទេ។



Scanned with CamScanner

**ជ. អំពី សេចក្ដីសម្រេចពិសេសលើការបង្គាប់ឱ្យចាប់ខ្លួន ឬការបង្គាប់ឱ្យឃុំខ្លួន**

ផ្អែកតាមភស្តុតាង និងតាមរយៈកិច្ចពិភាក្សាដេញដោលក្នុងសវនាការ បង្ហាញថា តាមកាលៈទេសៈនៃបទល្មើស តាមបុគ្គលិកលក្ខណៈនៃជនជាប់ចោទ តាមសភាពផ្លូវចិត្ត តាមធនធាននិងបន្ទុក តាមមូលហេតុ ព្រមទាំងកិរិយាមារយាទរបស់ជនជាប់ចោទ ក្រោយពេលប្រព្រឹត្តបទល្មើស តុលាការសម្រេចឱ្យចាប់ខ្លួនជនជាប់ចោទឈ្មោះ [redacted] **សីហោ** ហៅ **ទ្រី** ភេទប្រុស កើតឆ្នាំ១៩៨៣ (អាយុ ៤០ ឆ្នាំ) ដូចមានអត្តសញ្ញាណខាងលើ។

**ឈ. អំពី វត្ថុចាប់យក**

វត្ថុចាប់យករួមមាន សារធាតុញៀនចំនួន **១ (មួយ)** កញ្ចប់តូច ទម្ងន់ **០,១៨ (សូន្យក្បៀសដប់ប្រាំបី)** **ក្រាម** វិចខ្ចប់ដាក់ក្នុងស្រោមសំបុត្រធំ១ ពណ៌ស បិទជិត គ្មានលេខកូដ ទូរស័ព្ទចំនួន **២ (ពីរ)** គ្រឿង ម៉ាកសាំស៊ុង ពណ៌ខ្មៅ (ចាស់បាក់បែក) និងម៉ាកខេមហ្វូន ពណ៌ផ្កាឈូក (ចាស់បាក់បែក) កូនកាបូបរូបតុកក្តាចំនួន ១ (មួយ) និងសម្ភារៈប្រើប្រាស់វេចខ្ចប់ថ្នាំញៀនមួយចំនួន ដែលត្រូវបានចាប់យកពីជនជាប់ចោទឈ្មោះ [redacted] **ចិត្រា** ឈ្មោះ [redacted] **ជីវ័ន្ត** ឈ្មោះ [redacted] **សុខជា** និងឈ្មោះ [redacted] **វណ្ណនា** គឺជាឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយដែលបានប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើស ឬដែលសម្រាប់ប្រព្រឹត្តបទល្មើសវត្ថុ ឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស។ ហេតុដូច្នេះ តុលាការនឹងសម្រេចរឹបអូសវត្ថុចាប់យកទាំងអស់ដែលបានចាប់យក។

## សេចក្ដីសម្រេច

**ក. ប្រកាសថា មានពិរុទ្ធភាពលើជនជាប់ចោទ៖**

១. ឈ្មោះ [redacted] **ចិត្រា** ភេទប្រុស កើតឆ្នាំ១៩៩៦ (អាយុ ២៧ ឆ្នាំ) ដូចមានអត្តសញ្ញាណខាងលើ ពីបទ **រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិលេខ១ សង្កាត់ស្វាយរលំ ក្រុងតាខ្មៅ ខេត្តកណ្ដាល កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្តន្ទាទោសតាមមាត្រ ៤០ កថាខណ្ឌទី១ ទី៤ និងមាត្រា ៤៥ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**២.** ឈ្មោះ [redacted] **ជីវ័ន្ត** ភេទប្រុស កើតឆ្នាំ២០០៧ (អាយុ ១៦ ឆ្នាំ) ដូចមានអត្តសញ្ញាណខាងលើ ពីបទ **រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិលេខ១ សង្កាត់ស្វាយរលំ ក្រុងតាខ្មៅ ខេត្តកណ្ដាល កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្តន្ទាទោសតាមមាត្រ ៤០ កថាខណ្ឌទី១ ទី៤ និងមាត្រា ៤៥ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៣. ឈ្មោះ [redacted] **សុខជា** ភេទប្រុស កើតឆ្នាំ១៩៩៤ (អាយុ ២៩ ឆ្នាំ) ដូចមានអត្តសញ្ញាណខាងលើ ពីបទ **រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិលេខ១ សង្កាត់ស្វាយរលំ ក្រុងតាខ្មៅ ខេត្តកណ្ដាល កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្តន្ទាទោសតាមមាត្រ ៤០ កថាខណ្ឌទី១ ទី៤ និងមាត្រា ៤៥ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។



Scanned with CamScanner

៤. ឈ្មោះ [redacted] **វឌ្ឍណា** ភេទប្រុស កើតឆ្នាំ២០០២ (អាយុ ២១ ឆ្នាំ) ដូចមានអត្តសញ្ញាណខាងលើ ពីបទ **រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិលេខ១ សង្កាត់ស្វាយរលំ ក្រុងតាខ្មៅ ខេត្តកណ្ដាល កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្ដន្ទាទោសតាមមាត្រ ៤០ កថាខណ្ឌទី១ ទី៤ និងមាត្រា ៤៥ កថាខណ្ឌទី១ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

៥. ឈ្មោះ [redacted] **សីហោ** ហៅ **ទ្រី** ភេទប្រុស កើតឆ្នាំ១៩៨៣ (អាយុ ៤០ ឆ្នាំ) ដូចមានអត្តសញ្ញាណខាងលើ ពីបទ **រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិលេខ១ សង្កាត់ស្វាយរលំ ក្រុងតាខ្មៅ ខេត្តកណ្ដាល កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្ដន្ទាទោសតាមមាត្រ ៤០ កថាខណ្ឌទី១ ទី៤ និងមាត្រា ៤៥ កថាខណ្ឌទី១ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

**ខ. ផ្ដន្ទាទោសជាទោសដាក់ពន្ធនាគារលើជនជាប់ចោទ៖**

១. ឈ្មោះ [redacted] **ចិត្រា** ភេទប្រុស កើតឆ្នាំ១៩៩៦ (អាយុ ២៧ ឆ្នាំ) ដូចមានអត្តសញ្ញាណខាងលើ ចំនួន **២ (ពីរ) ឆ្នាំ** ពីបទ **រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិលេខ១ សង្កាត់ស្វាយរលំ ក្រុងតាខ្មៅ ខេត្តកណ្ដាល កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្ដន្ទាទោសតាមមាត្រ ៤០ កថាខណ្ឌទី១ ទី៤ និងមាត្រា ៤៥ កថាខណ្ឌទី១ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

២. ឈ្មោះ [redacted] **ជីវ័ន្ត** ភេទប្រុស កើតឆ្នាំ២០០៧ (អាយុ ១៦ ឆ្នាំ) ដូចមានអត្តសញ្ញាណខាងលើ ចំនួន **១ (មួយ) ឆ្នាំ** ពីបទ **រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិលេខ១ សង្កាត់ស្វាយរលំ ក្រុងតាខ្មៅ ខេត្តកណ្ដាល កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្ដន្ទាទោសតាមតាមមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ មាត្រ ៤០ កថាខណ្ឌទី១ ទី៤ និងមាត្រា ៤៥ កថាខណ្ឌទី១ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

៣. ឈ្មោះ [redacted] **សុខជា** ភេទប្រុស កើតឆ្នាំ១៩៩៤ (អាយុ ២៩ ឆ្នាំ) ដូចមានអត្តសញ្ញាណខាងលើ ចំនួន **២ (ពីរ) ឆ្នាំ** ពីបទ **រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិលេខ១ សង្កាត់ស្វាយរលំ ក្រុងតាខ្មៅ ខេត្តកណ្ដាល កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្ដន្ទាទោសតាមមាត្រ ៤០ កថាខណ្ឌទី១ ទី៤ និងមាត្រា ៤៥ កថាខណ្ឌទី១ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

៤. ឈ្មោះ [redacted] **វឌ្ឍណា** ភេទប្រុស កើតឆ្នាំ២០០២ (អាយុ ២១ ឆ្នាំ) ដូចមានអត្តសញ្ញាណខាងលើ ចំនួន **២ (ពីរ) ឆ្នាំ** ពីបទ **រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិលេខ១ សង្កាត់ស្វាយរលំ ក្រុងតាខ្មៅ ខេត្តកណ្ដាល កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣ បទ



Scanned with CamScanner

ល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្តន្ទាទោសតាមមាត្រ ៤០ កថាខណ្ឌទី១ ទី៤ និងមាត្រា ៤៥ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**៥.** ឈ្មោះ [redacted] **សីហោ** ហៅ **ថ្វី** ភេទប្រុស កើតឆ្នាំ១៩៨៣ (អាយុ ៤០ ឆ្នាំ) ដូចមានអត្តសញ្ញាណខាងលើ ចំនួន **២ (ពីរ) ឆ្នាំ** ពីបទ **រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិលេខ១ សង្កាត់ស្វាយរលំ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្តន្ទាទោសតាមមាត្រ ៤០ កថាខណ្ឌទី១ ទី៤ និងមាត្រា ៤៥ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

គ. បង្គាប់ឱ្យចាប់ខ្លួនជនជាប់ចោទឈ្មោះ[redacted] **សីហោ** ហៅ **ថ្វី** ភេទប្រុស កើតឆ្នាំ១៩៨៣ (អាយុ ៤០ ឆ្នាំ) ដូចមានអត្តសញ្ញាណខាងលើ តាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**ឃ.** វត្ថុចាប់យកដែលរួមមាន សារធាតុញៀនចំនួន **១ (មួយ)** កញ្ចប់តូច ទម្ងន់ **0,១៨ (សូន្យក្បៀសដប់ប្រាំបី) ក្រាម** វិចខ្ចប់ដាក់ក្នុងស្រោមសំបុត្រធំ១ ពណ៌ស បិទជិត គ្មានលេខកូដ ទូរស័ព្ទចំនួន **២ (ពីរ)** គ្រឿង ម៉ាកសាំស៊ុង ពណ៌ខ្មៅ (ចាស់បាក់បែក) និងម៉ាកខេមហ្វូន ពណ៌ ផ្កាឈូក (ចាស់បាក់បែក) កូនកាបូបរូបតុក្កតាចំនួន ១ (មួយ) និងសម្ភារៈប្រើប្រាស់វេចខ្ចប់ថ្នាំញៀនមួយចំនួន ត្រូវរឹបអូស។

*សំណុំរឿងព្រហ្មទណ្ឌនេះជំនុំជម្រះជាសាធារណៈ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ចិត្រា ឈ្មោះ [redacted] ជីវ័ន្ត ឈ្មោះ [redacted] សុខជា ឈ្មោះ [redacted] វណ្ណនា និងកំបាំងមុខជនជាប់ចោទឈ្មោះ [redacted] សីហោ ហៅ ថ្វី។*

*សំណុំរឿងព្រហ្មទណ្ឌនេះ ត្រូវបានជំនុំជម្រះជាសាធារណៈ នៅចំពោះមុខជនជាប់ជាប់។*

*ភាគីដែលមានបំណងធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសាលក្រមនេះ ត្រូវធ្វើតាមការកំណត់របស់ច្បាប់។*

**ក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម**

| ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា និងត្រា [redacted] | ហត្ថលេខា និងត្រា [redacted] | ហត្ថលេខា និងត្រា [redacted] |

**ក្រឡាបញ្ជីសវនាការ**

ហត្ថលេខា និងត្រា [redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃ ពុធ ២ កើត ខែចេត្រ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

ខេត្តកណ្តាល ថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៤

**ក្រឡាបញ្ជីសវនាការ**

[redacted]

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]



Scanned with CamScanner